# ព្រឹត្តិបត្រព័ត៌មាន

មូលនិធិគាំទ្រការបណ្ដុះបណ្ដាលសុខភាពសិក្សា និងការលើកកម្ពស់អេកូសុខភាព

លេខ ៤ | ថ្ងៃអង្គារ ១៤កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹង ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៦

## កិច្ចប្រជុំលើកទី១នៃគណៈកម្មការអនុវត្តគម្រោង

*«ការពង្រឹងកិច្ចសហការ និងជំរុញការអនុវត្តគម្រោងអភិវឌ្ឍសុខភាពសិក្សាសម្រាប់កុមារកម្ពុជា - ដំណាក់កាលទី ២»*


© ក្រសួងអប់រំ យុវជន និងកីឡា

រាជធានីភ្នំពេញ៖ នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៦ **លោកជំទាវបណ្ឌិត គឹម សេដ្ឋានី រដ្ឋលេខាធិការប្រចាំការ ក្រសួងអប់រំ យុវជន និងកីឡា** និងជានាយកគ្រប់គ្រងគម្រោង បានចូលរួមជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មការនៃការអនុវត្តគម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា ដំណាក់កាលទី២ (២០២៦-២០២៨) របស់អង្គការមូលនិធិគាំទ្រការបណ្ដុះបណ្ដាលសុខភាពសិក្សា និងលើកកម្ពស់អេកូសុខភាព (School Health Training and Ecohealth Promotion Foundation - STEP) គាំទ្រដោយមូលនិធិនីបប៉ុន (The Nippon Foundation) ក្នុងការលើកកម្ពស់សុខភាពសិក្សានៅប្រទេសកម្ពុជា ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា តំណាងដៃគូអភិវឌ្ឍន៍ និងមន្ត្រីពាក់ព័ន្ធក្រោមឱវាទ។

កិច្ចប្រជុំត្រូវបានរៀបចំឡើង ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោងដំណាក់កាលទី២ ក្នុងរយៈពេល៥ខែកន្លងមកនេះ ដោយមានកិច្ចសហការជាមួយនាយកដ្ឋានសុខភាពសិក្សា វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង។ គម្រោងដំណាក់កាលទី២នេះផ្ដោតសំខាន់លើការបង្កើតមុខវិជ្ជាឯកទេសសុខភាពសិក្សា សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ តាមរយៈការអភិវឌ្ឍកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត សៀវភៅសិក្សាគោល និងការបណ្ដុះបណ្ដាលគ្រូឧទ្ទេសឯកទេសសុខភាពសិក្សាថ្នាក់ជាតិ ស្របតាមផែនការសកម្មភាពជាតិស្ដីពីសុខភាពសិក្សា ឆ្នាំ២០២១-២០៣០។

ក្នុងឱកាសនេះ លោកជំទាវបណ្ឌិត រដ្ឋលេខាធិការប្រចាំការ បានថ្លែងអំណរគុណចំពោះអង្គការ STEP និងមូលនិធិនីបប៉ុន (The Nippon Foundation) ដែលតែងតែផ្ដល់ការគាំទ្រយ៉ាងពេញទំហឹងដល់វិស័យអប់រំនៅប្រទេសកម្ពុជា និងជឿជាក់យ៉ាងមុតមាំថា គម្រោងដំណាក់កាលទី២នេះ នឹងក្លាយជាគ្រឹះយ៉ាងរឹងមាំក្នុងការកសាងធនធានមនុស្សដែលមានទាំងចំណេះដឹង និងសុខភាពល្អ ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើន។

ជាមួយគ្នានេះផងដែរ លោកជំទាវបណ្ឌិត រដ្ឋលេខាធិការប្រចាំការ បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានាដែលកើតចេញពីកិច្ចសហការយ៉ាងល្អរវាងនាយកដ្ឋានសុខភាពសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍកម្មវិធី និងធនធានសិក្សាសម្រាប់វិស័យសុខភាពសិក្សានៅកម្ពុជា៕


លោកជំទាវបណ្ឌិត គឹម សេដ្ឋានី រដ្ឋលេខាធិការប្រចាំការ ក្រសួងអប់រំ យុវជន និងកីឡា

# វគ្គបណ្ដុះបណ្ដាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី៣

## ខែកក្កដា ទី១៣–១៦ ឆ្នាំ២០២៦ | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង

### ការពង្រឹងគុណភាពអប់រំសុខភាពសិក្សា តាមរយៈការរៀនសូត្រ ការចែករំលែកចំណេះដឹង និងការអនុវត្តជាក់ស្ដែង

អង្គការ STEP គាំទ្រដោយមូលនិធិនីបប៉ុន (The Nippon Foundation) បានរៀបចំដោយជោគជ័យនូវ **«វគ្គបណ្ដុះបណ្ដាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី៣»** រយៈពេល ៤ថ្ងៃ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៣–១៤ ខែកក្កដា ឆ្នាំ២០២៦ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងថ្ងៃទី១៥–១៦ ខែកក្កដា ឆ្នាំ២០២៦ នៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង។

វគ្គបណ្ដុះបណ្ដាលនេះមានការចូលរួមពីសាស្ត្រាចារ្យជំនាញមកពីប្រទេសជប៉ុន តំណាងមកពីអង្គភាពពាក់ព័ន្ធ គណៈគ្រប់គ្រង គ្រូឧទ្ទេសសុខភាពសិក្សា លោកគ្រូ អ្នកគ្រូនៃសាលាបឋមសិក្សាអនុវត្តន៍ និងអនុវិទ្យាល័យ ព្រមទាំងគរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យទាំង២។
តាមរយៈការធ្វើបទបង្ហាញ ការពិភាក្សា និងការអនុវត្តជាក់ស្ដែងពាក់ព័ន្ធនឹងការអប់រំសុខភាព អាហារូបត្ថម្ភ ការគ្រប់គ្រងបន្ទប់សុខភាព និងការធ្វើចលនាបេះដូង និងសួតឱ្យដំណើរការឡើងវិញ(CPR) និងឧបករណ៍ស្ទង់ចរន្តបេះដូងស្វ័យប្រវត្តិ (AED) អ្នកចូលរួមបានពង្រឹងចំណេះដឹងជំនាញវិជ្ជាជីវៈ និងសមត្ថភាពអនុវត្ត ដើម្បីលើកកម្ពស់គុណភាពអប់រំសុខភាពសិក្សា និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះស្ថានភាពបន្ទាន់នៅក្នុងសាលារៀន។



### មតិស្វាគមន៍ពីនាយិកាប្រចាំប្រទេស




**កញ្ញា** Yuka បានមានមតិស្វាគមន៍ដល់គណៈគ្រប់គ្រង គ្រូឧទ្ទេសសុខភាពសិក្សា លោកគ្រូ អ្នកគ្រូ និងគរុនិស្សិតដែលបានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាល ព្រមទាំងបានថ្លែងអំណរគុណចំពោះការប្ដេជ្ញាចិត្ត និងការគាំទ្ររបស់អ្នកចូលរួមចំពោះគម្រោង STEP។ កញ្ញាបានគូសបញ្ជាក់ពីសារៈសំខាន់នៃ វគ្គបណ្ដុះបណ្ដាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី៣ ដែលបានពង្រីកវិសាលភាពទៅលើការគ្រប់គ្រងបន្ទប់សុខភាពសិក្សា និងការផ្លាស់ប្ដូរបទពិសោធន៍រវាងអ្នកចូលរួម។

ជាមួយគ្នានេះ **កញ្ញា** បានស្វាគមន៍យ៉ាងកក់ក្ដៅចំពោះ លោកស្រី**សាស្ត្រាចារ្យ** Saito និងលោកស្រី**សាស្ត្រាចារ្យ** Nakamura មកពីប្រទេសជប៉ុន និងលើកទឹកចិត្តដល់អ្នកចូលរួមឱ្យចូលរួមយ៉ាងសកម្ម ផ្លាស់ប្ដូរចំណេះដឹង និងទាញយកអត្ថប្រយោជន៍ជាអតិបរមាពីឱកាសសិក្សាដ៏មានតម្លៃនេះ។

កញ្ញា Masuko Yuka | នាយិកាប្រចាំប្រទេសនៃអង្គការ STEP

### មតិសំណេះសំណាលពី ប្រធានអង្គការ



**លោកសាស្ត្រាចារ្យបណ្ឌិត** Asakura បានធ្វើបទបង្ហាញគន្លឹះស្ដីពីសារៈសំខាន់នៃ សុខភាពសិក្សាជាសកល ដោយបានគូសបញ្ជាក់ពីតួនាទីដ៏សំខាន់របស់សុខភាពសិក្សាក្នុងការលើកកម្ពស់ការអប់រំ សុខភាព និងសុខុមាលភាពរបស់កុមារ។ លោកបានបង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងសុខភាពសិក្សា និងការអប់រំ ព្រមទាំងសារៈសំខាន់របស់សាលារៀនក្នុងការលើកកម្ពស់អាហារូបត្ថម្ភ សុខភាពផ្លូវចិត្ត អនាម័យ ការការពារកុមារ និងសមភាព តាមរយៈ **វិធីសាស្ត្រសាលារៀនទាំងមូល** (Whole-School Approach)។

លោកសាស្ត្រាចារ្យ បានលើកទឹកចិត្តដល់អ្នកចូលរួមឱ្យបន្តពង្រឹងការប្ដេជ្ញាចិត្តក្នុងការអប់រំសុខភាពសិក្សា ដើម្បីរួមចំណែកដល់ការអភិវឌ្ឍកុមារ និងការកសាងអនាគតប្រកបដោយសុខភាពល្អប្រសើរ។

លោកសាស្ត្រាចារ្យបណ្ឌិត Asakura Takashi | ប្រធានអង្គការ STEP

# វគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី៣

## ថ្ងៃទី១៖ ការកសាងមូលដ្ឋានគ្រឹះ ដោយផ្តោតលើការអប់រំអាហារូបត្ថម្ភ

**ខែកក្កដា ទី១៣ ឆ្នាំ២០២៦ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**

នៅរសៀលថ្ងៃចន្ទ ១៤រោច ខែបឋមសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ត្រូវនឹងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៦ ដែលជាថ្ងៃទី១ នៃវគ្គបណ្តុះបណ្តាល អង្គការ STEP គាំទ្រដោយមូលនិធិនីបប៉ុន (The Nippon Foundation) បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី៣ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ ពិធីបើកវគ្គបណ្តុះបណ្តាលនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព **លោក ម៉ន មុនិន្ទ** ប្រធាននាយកដ្ឋានកិច្ចការបណ្តុះបណ្តាល នៃក្រសួងអប់រំ យុវជន និងកីឡា ដោយមានការចូលរួមពីគ្រូឧទ្ទេសសុខភាពសិក្សានៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ព្រមទាំងគ្រូបង្រៀនសុខភាពមកពីសាលាអនុវត្តរាជធានីភ្នំពេញ និងអនុវិទ្យាល័យអូរបែកក្អម។

ក្នុងកម្មវិធីថ្ងៃទី១នេះផងដែរ **សាស្ត្រាចារ្យ Nakamura** មកពីសាកលវិទ្យាល័យ Jumonji ប្រទេសជប៉ុន បានធ្វើបទបង្ហាញក្រោមប្រធានបទ **«មុខងារ និងតួនាទីនៃអាហារូបត្ថម្ភ»** ដោយបានចែករំលែកចំណេះដឹង និងបទពិសោធន៍សំខាន់ៗ អំពីសារៈសំខាន់នៃអាហារូបត្ថម្ភក្នុងការលើកកម្ពស់សុខភាព និងការអភិវឌ្ឍរបស់សិស្ស។











## វឌ្ឍនភាពនៃគោលនយោបាយសុខភាពសិក្សា

**លោក ម៉ន មុនិន្ទ** បានគូសបញ្ជាក់ពីវឌ្ឍនភាពក្នុងការពង្រឹង សុខភាពសិក្សា តាមរយៈការគាំទ្រផ្នែកគោលនយោបាយ និងបច្ចេកទេសពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍។ លោកបានលើកឡើងពីសមិទ្ធផលសំខាន់ៗ រួមមានការដាក់បញ្ចូលសុខភាពជាអាទិភាពក្នុង ស្តង់ដារគ្រូបង្រៀនដែលបានកែសម្រួលថ្មី ការលើកកម្ពស់កម្មវិធីអាហារូបត្ថម្ភ និងការដាក់ចេញគោលការណ៍ណែនាំស្តីពីបរិយាកាសសាលារៀនមានសុខភាពល្អ។ ជាមួយគ្នានេះ លោកក៏បានទទួលស្គាល់នូវការគាំទ្រដ៏សំខាន់ពី **លោកជំទាវបណ្ឌិត គឹម សេដ្ឋានី** រដ្ឋលេខាធិការប្រចាំការ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការជំរុញការអប់រំសុខភាព និងការអនុវត្តគម្រោង STEP។

លោកក៏បានគូសបញ្ជាក់ពីសមិទ្ធផលផ្នែកបច្ចេកទេសដូចជា ការអភិវឌ្ឍសៀវភៅសិក្សាអប់រំសុខភាព ការបញ្ចូលមុខវិជ្ជាសុខភាពសិក្សាទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូ និងការរៀបចំម៉ូឌុលបណ្តុះបណ្តាលសុខភាពសិក្សា ដោយអង្គការ STEP សហការជាមួយ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង។






លោក ម៉ន មុនិន្ទ | ប្រធាននាយកដ្ឋានកិច្ចការបណ្តុះបណ្តាល

## ពីចំណេះដឹងឆ្ពោះទៅកាន់ឧត្តមានុវត្តន៍

**ឯកឧត្តមបណ្ឌិត សិត សេង** បានលើកទឹកចិត្តដល់គ្រូឧទ្ទេសសុខភាពសិក្សា និងគ្រូបង្រៀននៅសាលាអនុវត្ត ឱ្យយកចំណេះដឹង និងវិធីសាស្ត្របង្រៀនដែលទទួលបានពីវគ្គបណ្តុះបណ្តាលទៅអនុវត្តក្នុងការបង្រៀនជាក់ស្តែង។ ឯកឧត្តមបានគូសបញ្ជាក់ពីសារៈសំខាន់នៃការលើកកម្ពស់សមត្ថភាពគិតវិភាគ ការដោះស្រាយបញ្ហា និងការច្នៃប្រឌិតរបស់សិស្ស ដែលគួរត្រូវបានបញ្ចូលក្នុងការបង្រៀនគ្រប់មុខវិជ្ជា មិនមែនត្រឹមតែការអប់រំសុខភាពសិក្សាប៉ុណ្ណោះទេ។

ឯកឧត្តមក៏បានលើកទឹកចិត្តដល់អ្នកចូលរួមឱ្យបន្តចែករំលែកចំណេះដឹង បទពិសោធន៍ និងការអនុវត្តល្អៗដែលទទួលបានពីវគ្គបណ្តុះបណ្តាល ទៅកាន់សហការីនៅក្នុងវិទ្យាស្ថានរបស់ខ្លួន ដោយចាប់ផ្តើមពីកម្រិតបុគ្គល បន្តទៅកម្រិតដេប៉ាតឺម៉ង់ និងពង្រីកដល់កម្រិតវិទ្យាស្ថានទាំងមូល ដើម្បីរួមចំណែកពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូ។

ជាចុងក្រោយ ឯកឧត្តមបណ្ឌិត បានថ្លែងអំណរគុណដល់អង្គការ STEP មូលនិធិនីប៉ុន (The Nippon Foundation) ឯកឧត្តមវេជ្ជបណ្ឌិត យង់ គន្ធារិទ្ធ សាស្ត្រាចារ្យជប៉ុន និងអ្នកចូលរួមទាំងអស់ ចំពោះការគាំទ្រ កិច្ចសហការ និងការប្តេជ្ញាចិត្តជាបន្តបន្ទាប់ ក្នុងការលើកកម្ពស់ការអប់រំសុខភាពសិក្សា និងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

ឯកឧត្តមបណ្ឌិត សិត សេង | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ





ការប្រគល់សៀវភៅសុខភាពសិក្សាកម្រិតបឋមចំនួន ១៦៤ក្បាល ជូនវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

## វឌ្ឍនភាពស្តីពីសុខភាពសិក្សានៅកម្ពុជា






**ឯកឧត្តមវេជ្ជបណ្ឌិត យង់ គន្ធារិទ្ធ** បានធ្វើបទបង្ហាញអំពីវឌ្ឍនភាពនៃការអភិវឌ្ឍសុខភាពសិក្សានៅកម្ពុជា ដោយលើកឡើងពីសមិទ្ធផលសំខាន់ៗក្នុងការពង្រីកបន្ទប់សុខភាពសិក្សា ការលើកកម្ពស់កម្មវិធីអាហារូបត្ថម្ភ និងការពង្រឹងលទ្ធភាពទទួលបានសេវាសុខភាពនៅតាមគ្រឹះស្ថានសិក្សា។ ឯកឧត្តមបានបញ្ជាក់ថា ការអប់រំសុខភាពមានតួនាទីសំខាន់ក្នុងការលើកកម្ពស់គុណភាពអប់រំ និងបានវាយតម្លៃខ្ពស់ចំពោះការគាំទ្ររបស់គម្រោង STEP ក្នុងការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសសុខភាពសិក្សា ព្រមទាំងការកែលម្អសម្ភារៈបង្រៀន និងរៀន។

លើសពីនេះ ឯកឧត្តមបានគូសបញ្ជាក់ពីសារៈសំខាន់នៃកម្មវិធីសិក្សា ២៤ ក្រេឌីត ក្រោមស្តង់ដារវិជ្ជាជីវៈសម្រាប់ការអប់រំគ្រូ ដែលជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សាប្រកបដោយវិជ្ជាជីវៈ។ លោកក៏បានថ្លែងអំណរគុណចំពោះការគាំទ្រផ្នែកបច្ចេកទេសពីសាស្ត្រាចារ្យជប៉ុន ក្នុងការរៀបចំសម្ភារៈសិក្សា និងសៀវភៅគោលសុខភាពសិក្សា ដែលគ្រោងនឹងទទួលស្គាល់ជាផ្លូវការ។

ឯកឧត្តមវេជ្ជបណ្ឌិត យង់ គន្ធារិទ្ធ | អនុប្រធាននាយកដ្ឋានសុខភាពសិក្សា

# វគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី៣

## ថ្ងៃទី២៖ ការពង្រឹងសមត្ថភាព ក្នុងការអនុវត្ត CPR និង AEDs ខែកក្កដា ទី១៤ ឆ្នាំ២០២៦ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

នាព្រឹកថ្ងៃអង្គារ ១៥រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ត្រូវនឹងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៦ ដែលជាថ្ងៃទី២នៃវគ្គបណ្តុះបណ្តាល អង្គការ STEP គាំទ្រដោយ មូលនិធិនីបប៉ុន (The Nippon Foundation) បានបន្តរៀបចំ «**វគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី៣**» នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ កម្មវិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត យង់ គន្ធារិទ្ធ** អនុប្រធាននាយកដ្ឋានសុខភាពសិក្សា និង **ឯកឧត្តមបណ្ឌិត សិត សេង** នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដោយមានការចូលរួមពីគ្រូឧទ្ទេសសុខភាពសិក្សានៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង ព្រមទាំងគ្រូបង្រៀនសុខភាពមកពីសាលាបឋមសិក្សាអនុវត្តរាជធានី និងអនុវិទ្យាល័យអូរបែកក្អម និងគរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។

ក្នុងកម្មវិធីនេះ សាស្ត្រាចារ្យ Saito មកពីសាកលវិទ្យាល័យ Saitama ប្រទេសជប៉ុនបានធ្វើបទបង្ហាញក្រោមប្រធានបទ «ការធ្វើចលនាបេះដូងនិងសួតឱ្យដំណើរការឡើងវិញ (CPR)» និងការប្រើប្រាស់«ឧបករណ៍ស្ទង់ចរន្តបេះដូងស្វ័យប្រវត្តិ (AED)» ដោយផ្តល់ជូនអ្នកចូលរួមនូវចំណេះដឹងចាំបាច់ និងជំនាញអនុវត្តជាក់ស្តែង ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះស្ថានភាពបន្ទាន់ដែលពាក់ព័ន្ធនឹងបេះដូង។

ថ្ងៃទី២ នៃវគ្គបណ្តុះបណ្តាលបានបញ្ចប់ដោយសកម្មភាពអនុវត្តជាក្រុមលើបច្ចេកទេស CPR និងការប្រើប្រាស់ AED ដែលបានផ្តល់ឱ្យអ្នកចូលរួមនូវឱកាសពង្រឹងចំណេះដឹង ជំនាញអនុវត្ត និងទំនុកចិត្តក្នុងការឆ្លើយតបចំពោះស្ថានភាពបន្ទាន់។ សកម្មភាពនេះមានគោលបំណងពង្រឹងសមត្ថភាពគ្រូឧទ្ទេសសុខភាពសិក្សា និងគ្រូបង្រៀនសុខភាពសិក្សា លើកកម្ពស់គុណភាពអប់រំសុខភាពសិក្សា និងរួមចំណែកបង្កើតបរិយាកាសសិក្សាដែលមានសុវត្ថិភាព និងលើកកម្ពស់សុខុមាលភាពរបស់សិស្សានុសិស្ស។










សកម្មភាព៖ ការពង្រឹងសមត្ថភាពឆ្លើយតបក្នុងគ្រាអាសន្ន តាមរយៈជំនាញ CPR និង AED

## ការប្រែក្លាយចំណេះដឹងទៅជាការជួយសង្គ្រោះជីវិត(Basic Life Support)

បន្ទាប់ពីបានទទួលចំណេះដឹង និងជំនាញអនុវត្តដែលបានចែករំលែកដោយសាស្ត្រាចារ្យ Saito **លោកស្រី ហួរ ឃីម** គ្រូឧទ្ទេសសុខភាពសិក្សា នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានដឹកនាំវគ្គបណ្តុះបណ្តាលបន្តសម្រាប់គរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដោយបន្តផ្ទេរចំណេះដឹងសំខាន់ៗ និងវិធីសាស្ត្របង្រៀនស្តីពីការធ្វើCPR។ តាមរយៈការធ្វើបទបង្ហាញ និងការអនុវត្តក្រោមការណែនាំ លោកស្រីបានពង្រឹងជំនាញឆ្លើយតបក្នុងគ្រាអាសន្ន ព្រមទាំងជំរុញឱ្យគរុនិស្សិតអភិវឌ្ឍទំនុកចិត្ត និងសមត្ថភាពក្នុងការអនុវត្តបច្ចេកទេសសង្គ្រោះជីវិតនៅក្នុងបរិបទសាលារៀន។ ការបណ្តុះបណ្តាលបន្តតាមរយៈការផ្ទេរចំណេះដឹងនេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់គម្រោង STEP ក្នុងការពង្រឹងសមត្ថភាពគ្រូឧទ្ទេស និងគរុនិស្សិត ព្រមទាំងលើកកម្ពស់ការអប់រំសុខភាពសិក្សាប្រកបដោយចីរភាពនៅកម្ពុជា។





សកម្មភាព៖ លោកស្រី ហួរ ឃីម ធ្វើបទបង្ហាញអំពីបច្ចេកទេស CPR ដោយណែនាំ និងគាំទ្រគរុនិស្សិតក្នុងការអនុវត្តជំនាញសង្គ្រោះជីវិត

# វគ្គបណ្ដុះបណ្ដាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី៣

## ថ្ងៃទី៣៖ ការពង្រឹងសមត្ថភាពតាមរយៈការអនុវត្តជាក់ស្ដែង

**ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ វិទ្យាស្ថានគរុកោសល្យបាត់ដំបង**

ថ្ងៃពុធ ១កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ ដែលជាថ្ងៃទី៣នៃ «**វគ្គបណ្ដុះបណ្ដាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី៣**» បានរៀបចំឡើងនៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ជា វឌ្ឍា** នាយកវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដោយមានការចូលរួមពីគ្រូឧទ្ទេសសុខភាពសិក្សានៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង ព្រមទាំងគ្រូបង្រៀនសុខភាពមកពីសាលាបឋមសិក្សាអនុវត្ត និងអនុវិទ្យាល័យអនុវត្តនៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង និងគរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យបាត់ដំបង។










## សុខភាពកុមារជាមូលដ្ឋានគ្រឹះនៃការសិក្សា

**ឯកឧត្តមបណ្ឌិត ជា វឌ្ឍា** បានគូសបញ្ជាក់ថា ការអប់រំសុខភាពបានក្លាយជាអាទិភាពសកល ជាពិសេសនៅក្នុងយុគសម័យក្រោយវិបត្តិកូវីដ-១៩។ លោកបានលើកឡើងអំពីបញ្ហាប្រឈមថ្មីៗដែលកំពុងប៉ះពាល់ដល់កុមារ រួមមានការប្រើប្រាស់ស្មាតហ្វូនច្រើនហួសកម្រិត ការថយចុះនៃសកម្មភាពរាងកាយ ផលប៉ះពាល់លើការលូតលាស់រាងកាយ និងការកើនឡើងនៃបញ្ហាសុខភាពផ្លូវចិត្ត ដូចជា ភាពតានតឹង និងការលំបាកផ្នែកអារម្មណ៍។

បន្ថែមពីនេះ លោកបានបង្ហាញក្ដីបារម្ភអំពីការទទួលទានភេសជ្ជៈប៉ូវកម្លាំងច្រើនហួសកម្រិតរបស់កុមារ ដែលអាចបង្កផលប៉ះពាល់ដល់សុខភាព និងជះឥទ្ធិពលអវិជ្ជមានលើការផ្ដោតអារម្មណ៍ សមត្ថភាពសិក្សា និងអាកប្បកិរិយា។ ជាមួយគ្នានេះ របបអាហារមិនមានសុខភាពល្អ និងកង្វះអាហារូបត្ថម្ភ ត្រូវបានចាត់ទុកជាកត្តាដែលអាចប៉ះពាល់ដល់ការលូតលាស់រាងកាយ និងការអភិវឌ្ឍរបស់កុមារ។

ដោយទទួលស្គាល់នូវបញ្ហាទាំងនេះ លោកបានសង្កត់ធ្ងន់លើតួនាទីដ៏សំខាន់របស់គ្រូបង្រៀនក្នុងការ លើកកម្ពស់ការអប់រំសុខភាព ដោយសារសុខភាពល្អជាមូលដ្ឋានគ្រឹះ សម្រាប់ការសិក្សាប្រកបដោយប្រសិទ្ធភាព។ លោកបានបញ្ជាក់ថា ការគាំទ្រសុខភាពរបស់កុមារ នឹងជួយឱ្យពួកគេទទួលបានការសិក្សាកាន់តែប្រសើរ អភិវឌ្ឍសមត្ថភាពបានពេញលេញ និងក្លាយជាសសរស្តម្ភដ៏សំខាន់សម្រាប់ប្រទេសជាតិនាពេលអនាគត។

ឯកឧត្តមបណ្ឌិត ជា វឌ្ឍា | នាយកវិទ្យាស្ថានគរុកោសល្យបាត់ដំបង






ការប្រគល់សៀវភៅសុខភាពសិក្សាកម្រិតបឋមចំនួន ១៦២ក្បាល ជូនវិទ្យាស្ថានគរុកោសល្យបាត់ដំបង

## ថ្ងៃទី៤៖ ការរៀបចំធនធានសុខភាពសិក្សា

**ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៦ វិទ្យាស្ថានគរុកោសល្យបាត់ដំបង**






នៅថ្ងៃព្រហស្បតិ៍ ២កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៦ **«វគ្គបណ្ដុះបណ្ដាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី៣»** ដែលរៀបចំឡើងដោយអង្គការ STEP ក្រោមការគាំទ្រពីមូលនិធិនីប៉ុន (The Nippon Foundation) បានបញ្ចប់ដោយជោគជ័យនៅវិទ្យាស្ថានគរុកោសល្យបាត់ដំបង។

កម្មវិធីនៅថ្ងៃចុងក្រោយផ្ដោតលើការពិនិត្យឡើងវិញ និងកែសម្រួលសទ្ទានុក្រមសុខភាពសិក្សា ដើម្បីធានាឱ្យមានការប្រើប្រាស់ពាក្យបច្ចេកទេសក្នុងវិស័យអប់រំសុខភាពសិក្សាប្រកបដោយភាពត្រឹមត្រូវ និងស៊ីសង្វាក់គ្នា។ សទ្ទានុក្រមដែលបានឯកភាពនេះ នឹងត្រូវបញ្ចូលទៅក្នុងសៀវភៅសិក្សាគោល និងឯកសារបណ្ដុះបណ្ដាលផ្សេងៗ ដើម្បីពង្រឹងគុណភាព និងការអនុវត្តជាក់ស្ដែងនៃធនធានសិក្សាសម្រាប់ការបង្រៀននាពេលអនាគត។

**លោកបណ្ឌិត ហួត ស៊ីនុន** បានថ្លែងអំណរគុណដល់ អង្គការ STEP ចំពោះការគាំទ្រជាបន្តបន្ទាប់ក្នុងការលើកទឹកចិត្ត និងពង្រឹងសមត្ថភាពគ្រូឧទ្ទេសសុខភាពសិក្សា។ លោកបានគូសបញ្ជាក់ពីសារៈសំខាន់នៃការបណ្ដុះ បណ្ដាលដោយអនុវត្តជាក់ស្ដែងស្ដីពីការសង្គ្រោះតាមរយៈ CPR និងAED ដែលផ្ដល់ដោយសាស្ត្រាចារ្យជប៉ុននិងបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជំនាញរបស់គ្រូឧទ្ទេស និងគរុនិស្សិត។

លោកបានថ្លែងអំណរគុណដល់មូលនិធិនីប៉ុន (The Nippon Foundation) តាមរយៈអង្គការ STEP សាស្ត្រាចារ្យជប៉ុន និងដៃគូពាក់ព័ន្ធទាំងអស់ ចំពោះការចូលរួមចំណែកដ៏មានតម្លៃក្នុងការលើកកម្ពស់ការអប់រំគ្រូ និងការអភិវឌ្ឍសុខភាពសិក្សានៅកម្ពុជា។

លោកបណ្ឌិត ហួត ស៊ីនួន | នាយករងវិទ្យាស្ថានគរុកោសល្យបាត់ដំបង

## ពីបរិបទសាលារៀន ទៅការបង្រៀនប្រកបដោយប្រសិទ្ធភាព

**កញ្ញា** Masuko Yuka បានណែនាំអំពីគោលបំណង និងផែនការនៃដំណើរទស្សនកិច្ចសិក្សាទៅកាន់សាលារៀនជូនគ្រូឧទ្ទេសសុខភាពសិក្សា ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃទំនាក់ទំនងរវាងការបណ្ដុះបណ្ដាលគ្រូ និងបរិបទជាក់ស្ដែងនៅតាមសាលារៀន។ កញ្ញាបានពន្យល់ថា ដំណើរទស្សនកិច្ចនេះមានគោលបំណងស្វែងយល់អំពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តសុខភាពសិក្សានៅសាលាបឋមសិក្សា សិក្សាពីការអនុវត្តដែលមានស្រាប់ និងបញ្ហាប្រឈមនានា ព្រមទាំងយកចំណេះដឹង និងបទពិសោធន៍ដែលទទួលបានមកប្រើប្រាស់ ដើម្បីកែលម្អកិច្ចតែងការបង្រៀនសុខភាពសិក្សានៅវិទ្យាស្ថានគរុកោសល្យ។ វិធីសាស្ត្រនេះនឹងជួយធានាថា មេរៀននាពេលអនាគតមានលក្ខណៈអនុវត្តជាក់ស្ដែង មានភាពពាក់ព័ន្ធ និងឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់សាលារៀន និងសិស្សានុសិស្ស។




កញ្ញា MASUKO Yuka | នាយិកាប្រចាំប្រទេសនៃអង្គការ STEP

## ការពង្រឹងគុណភាពឯកសារសុខភាពសិក្សា



**លោក ថាយ សុខហេង** បានពិនិត្យវឌ្ឍនភាពនៃការបកប្រែសៀវភៅសុខភាពសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ និងពិភាក្សាអំពីបញ្ហាប្រឈមនានាដែល គ្រូឧទ្ទេសសុខភាពសិក្សាបានជួបប្រទះក្នុងអំឡុងពេលបកប្រែ។ កិច្ចពិភាក្សានេះបានផ្ដល់លទ្ធភាពដល់គ្រូឧទ្ទេសក្នុងការលើកឡើងពីចំណុចប្រឈម ចែករំលែកមតិយោបល់ និងផ្ដល់អនុសាសន៍ ដើម្បីស្វែងរកដំណោះស្រាយជាក់ស្ដែង ដែលធានាឱ្យការរៀបចំឯកសារសិក្សាមានភាពត្រឹមត្រូវ មានគុណភាព សមស្របតាម បរិបទ និងអាចបញ្ចប់បានទាន់ពេលវេលា។

លោក ថាយ សុខហេង | អគ្គលេខាធិការរងនៃអង្គការ STEP

## ល្បែងអាហារូបត្ថម្ភ SUGOROKU

គ្រូឧទ្ទេសសុខភាពសិក្សាបានស្វែងយល់អំពីល្បែងអប់រំអាហារូបត្ថម្ភSUGOROKU ជាមួយក្រុមការងារ STEP។ ឧបករណ៍សិក្សាបែបអន្តរកម្មនេះមានគោលបំណង លើកកម្ពស់ការអប់រំអាហារូបត្ថម្ភនៅតាមសាលារៀន ដោយលើកទឹកចិត្តឱ្យសិស្សស្វែងយល់អំពីទម្លាប់នៃការទទួលទានអាហារដែលមានសុខភាពល្អ តាមរយៈវិធីសាស្ត្រដែលមានភាពទាក់ទាញ និងរីករាយ។ តាមរយៈសកម្មភាពរៀនតាម រយៈល្បែងសិក្សានេះ អ្នកចូលរួមបានយល់កាន់តែច្បាស់អំពីការប្រើប្រាស់ឧបករណ៍បង្រៀនប្រកបដោយនវានុវត្តន៍ដើម្បីធ្វើឱ្យការអប់រំអាហារូបត្ថម្ភមានប្រសិទ្ធភាព មានអន្តរកម្ម និងឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សកាន់តែប្រសើរ។



## ការកែលម្អសទ្ទានុក្រមសុខភាពសិក្សា



កិច្ចប្រជុំពិនិត្យសទ្ទានុក្រម បានផ្តោតលើការពិនិត្យ និងកែលម្អពាក្យបច្ចេកទេសសំខាន់ៗក្នុងវិស័យសុខភាពសិក្សា ដើម្បីធានាឱ្យការប្រើប្រាស់ពាក្យមានភាពត្រឹមត្រូវ ស៊ីសង្វាក់គ្នា និងច្បាស់លាស់នៅក្នុងឯកសារបង្រៀន និងសិក្សា។ តាមរយៈការពិភាក្សារួមគ្នា អ្នកចូលរួមបានសហការក្នុងការកំណត់ការយល់ដឹងរួមអំពីនិយមន័យ និងការប្រើប្រាស់ពាក្យបច្ចេកទេស ដើម្បីគាំទ្រដល់ការបង្រៀន និងការរៀនសូត្រឱ្យកាន់តែមានប្រសិទ្ធភាព។



## ការឆ្លុះបញ្ចាំងពីបទពិសោធន៍ហាត់ការ

តាមរយៈការហាត់ការនៅអង្គការ STEP ខ្ញុំបានយល់កាន់តែច្បាស់បន្តិចម្តងៗថា គម្រោងសុខភាពសាធារណៈ និងសុខភាពសិក្សា ត្រូវបានគាំទ្រដោយការងារលម្អិតជាច្រើន ដែលមិនតែងតែអាចមើលឃើញពីខាងក្រៅបាន។ មុនពេលចាប់ផ្តើមការហាត់ការ ខ្ញុំតែងផ្តោតជាចម្បងលើខ្លឹមសារនៃសុខភាពសិក្សា ដូចជា ការអប់រំសុខភាព ការអនុវត្តអនាម័យ និងអាកប្បកិរិយារបស់កុមារ។ ប៉ុន្តែតាមរយៈការងារប្រចាំថ្ងៃ ខ្ញុំបានយល់ថា នៅពីក្រោយរាល់វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ និងឯកសារអប់រំនីមួយៗ មានការងារជាក់ស្តែងជាច្រើន ដូចជា ការរៀបចំឯកសារ ការរៀបចំទីតាំង ការរៀបចំ សម្ភារៈ ការរៀបចំបញ្ជីឈ្មោះអ្នកចូលរួម ការរៀបចំរបាយការណ៍ និងការសម្របសម្រួលទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធ។ ការឆ្លុះបញ្ចាំងដ៏សំខាន់មួយទៀត គឺទាក់ទងនឹងតម្លៃនៃការទំនាក់ទំនង និងការសម្របសម្រួលក្នុងការអនុវត្តគម្រោង។ ក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាល ខ្ញុំបានសង្កេតឃើញថា បុគ្គលិកអង្គការ STEP ត្រូវធ្វើការទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធជាច្រើន រួមមានគ្រូឧទ្ទេស គ្រូបង្រៀន ថ្នាក់ដឹកនាំក្រសួង និងដៃគូខាងក្រៅ។ ខ្ញុំបានរៀនថា ការទំនាក់ទំនងក្នុងការងារគម្រោង មិនមែនគ្រាន់តែជាការផ្លាស់ប្តូរព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែត្រូវការការយល់ពីតួនាទី ទស្សនៈ និងតម្រូវការរបស់អ្នកពាក់ព័ន្ធនីមួយៗ ការកែសម្រួលការពន្យល់ទៅតាមស្ថានភាព និងការបង្កើតបរិយាកាសដែលលើកទឹកចិត្តឱ្យមានការពិភាក្សា និងកិច្ចសហការ។

ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះរបៀបដែលបុគ្គលិកអង្គការ STEP បានកសាងទំនាក់ទំនងល្អ និងការជឿទុកចិត្តជាមួយអ្នកពាក់ព័ន្ធ ដោយបង្កើតបរិយាកាសនៃការគោរព និងកិច្ចសហការដូចជាគ្រួសារមួយ។ ការហាត់ការនេះបានផ្តល់ឱ្យខ្ញុំនូវបទពិសោធន៍ ចំណេះដឹង និងការយល់ដឹងថ្មីៗជាច្រើន ព្រមទាំងពង្រីកការយល់ដឹងរបស់ខ្ញុំអំពីការគ្រប់គ្រងគម្រោង ការងារជាក្រុម និងសារៈសំខាន់នៃកិច្ចសហការក្នុងការលើកកម្ពស់ការអភិវឌ្ឍសុខភាពសិក្សាប្រកបដោយចីរភាព។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការ STEP និងបុគ្គលិក STEP ទាំងអស់ដែលបានផ្តល់ឱកាសឱ្យខ្ញុំចូលរួមហាត់ការ ព្រមទាំងផ្តល់ការណែនាំ ការគាំទ្រ និងភាពកក់ក្តៅដល់ខ្ញុំក្នុងអំឡុងពេលហាត់ការ។




កញ្ញា Osaga Yuki
សាកលវិទ្យាល័យ Nagasaki

NEWSLETTER
School Health Training and Ecohealth Promotion Foundation

VOLUME 4 | 28 July, 2026

## The 1st STEP Steering Committee (SSC) Meeting

*"Strengthening Collaboration and Advancing Phase II of the School Health Development Project"*



©Ministry of Education Youth and Sport

On the morning of May 27, 2026, **H.E. Dr. Kim Sethany, Permanent Secretary of State of the Ministry of Education, Youth and Sport and Chair of SSC Meeting**, presided over the "The 1st STEP Steering Committee Meeting" (The 1st SSC) for the Phase II School Health Development Project for all Cambodian Children (2026–2028). The project is implemented by the School Health Training and Ecohealth Promotion Foundation (STEP) with support from The Nippon Foundation to promote school health in Cambodia. The meeting was attended by senior officials of the Ministry of Education, Youth and Sport, representatives of development partners, and relevant officials.

The meeting was organized to review the progress of Phase II implementation over the past five months, carried out in collaboration with the Department of School Health, Phnom Penh Teacher Education College, and Battambang Teacher Education College. This second phase focuses on establishing a specialized School Health subject at the lower secondary education level through the development of curricula, syllabi, core textbooks, and the training of national-level specialist school health lectures in line with the National Action Plan on School Health 2021–2030.

On this occasion, H.E. Dr. Kim Sethany expressed her gratitude to STEP and The Nippon Foundation for their continued and substantial support to Cambodia's education sector. Her Excellency expressed strong confidence that Phase II of the project would serve as a solid foundation for developing human resources equipped with both knowledge and good health, enabling them to contribute to the nation's continued development and prosperity.

At the same time, the Permanent Secretary of State highly commended the achievements resulting from the strong collaboration between the Ministry's Department of School Health, Phnom Penh Teacher Education College and Battambang Teacher Education College. Their active contributions to developing educational programs and learning resources have played an important role in advancing the school health sector in Cambodia.



*H.E. Dr. Kim Sethany, Permanent Secretary of State, MoEYS*

# The 3rd School Health Lecturer Training

**13–16 July 2026 | Phnom Penh Teacher Education College (PTEC) & Battambang Teacher Education College (BTEC)**

***Strengthening School Health Education through Knowledge Sharing and Practical Skills Development***

The NGO STEP, with the support of The Nippon Foundation, successfully organized **"The 3rd School Health Lecturer Training"** over four days, held on 13–14 July 2026 at PTEC and 15–16 July 2026 at BTEC. The training brought together Japanese expert professors, representatives from relevant departments, management teams, school health lecturers, teachers from attached primary and lower secondary schools, and student teachers of TECs. Through presentations, discussions, and practical sessions on school health education, nutrition, health room management, and Cardiopulmonary Resuscitation (CPR) and Automated External Defibrillator (AED), participants strengthened their professional knowledge and practical skills to enhance school health education and emergency response.



## Welcome Remark by Country Director

**Ms. Masuko Yuka** welcomed the management team, school health lecturers, teachers, and student teachers, expressing appreciation for their continued commitment to the STEP Project. She highlighted the importance of the 3rd School Health Lecturer Training, which expanded its focus to include school health room management and experience sharing. She also welcomed Ms. Saito and Dr. Nakamura from Japan, encouraging participants to actively engage, exchange knowledge, and maximize this valuable learning opportunity.



**Ms. Masuko Yuka | Country Director of STEP**

## Remark by Chairperson



**Prof. Dr. Asakura Takashi** delivered a keynote presentation on the global importance of School Health, emphasizing its essential role in improving children's education, health, and well-being. He highlighted the connection between school health and education, and the importance of schools in promoting nutrition, mental health, hygiene, child protection, and equity through a whole-school approach. He encouraged participants to strengthen their commitment to school health to support children's development and create a healthier future.

**Prof. Dr. Asakura Takashi | Chairperson of STEP**

## Day 1: Building the Foundation through *Nutrition Education*

**13 July 2026 | Phnom Penh Teacher Education College**

On the afternoon of 13 July 2026, the first day of the training program, NGO STEP officially launched **"The 3rd School Health Lecturer Training"** at Phnom Penh Teacher Education College. The opening ceremony was presided over by **Mr. Mon Munint**, Director of the Department of Teacher Education, Ministry of Education, Youth and Sport. The event brought together School Health lecturers from Phnom Penh and Battambang Teacher Education Colleges, as well as school health teachers from PTEC attached primary and lower secondary school.

As part of the first day's program, **Professor Nakamura** from Jumonji University, Japan, delivered a presentation entitled "Functions and Roles of Nutrition." She shared valuable knowledge and practical insights on the importance of nutrition in promoting students' health, growth, and overall development.











## Progress on School Health Policy

**Mr. Mon Munint** highlighted the progress made in strengthening School Health through policy and technical support from the Royal Government of Cambodia, MoEYS, and development partners. He noted key achievements, including the integration of health into the revised Teacher Standards, school nutrition initiatives, healthy school guidelines, and recognized the leadership support of **H.E. Dr. Kim Sethany**, permanent secretary of state in advancing school health education and the STEP Project. He also emphasized technical achievements such as the development of health education textbooks, integration of school health into teacher education curricula, and training modules developed by STEP in collaboration with Phnom Penh and Battambang Teacher Education Colleges.






Mr. Mon Munint  Director of Department of Teacher Education

## From Knowledge to Best Practice

**H.E. Dr. Set Seng** encouraged school health lecturers and teachers at the attached primary schools to apply the knowledge and teaching methodologies gained from the training in their actual classroom practice. He emphasized the importance of fostering students' critical thinking, problem-solving, and creativity, noting that these competencies should be integrated across all subjects, not only in School Health Education.

His excellency also encouraged participants to continue sharing the knowledge, experiences, and good practices gained from the training with their colleagues within their respective institutions, beginning at the individual level, expanding to the department level, and eventually throughout the entire Teacher Education College. This cascading approach will contribute to strengthening the quality of teacher education.

In his closing remarks, His excellency expressed his sincere appreciation to the STEP Project, The Nippon Foundation, H.E. Dr. Yung Kunthearith, the Japanese professors, and all participants for their continuous support, collaboration, and commitment to advancing School Health Education and strengthening the education sector in Cambodia.

**H.E. Dr. Set Seng**
**Director of Phnom Penh Teacher Education College**





Handover of 164 Primary School Health Textbooks to PTEC

## Progress in School Health in Cambodia






**H.E. Dr. Yung Kunthearith** provided updates on the progress of School Health Development in Cambodia, highlighting achievements in expanding school health facilities, strengthening school nutrition programmes, and improving access to health services in schools. He emphasized that strengthening school health education contributes directly to education quality and recognized the role of the STEP Project in enhancing the capacity of school health lecturers and improving teaching materials.

His Excellency also highlighted the importance of the 24-credit curriculum under the Professional Standards for Teacher Education in developing professional school health lecturers, acknowledged the support of Japanese professors in developing learning materials and the development of officially recognized core textbooks for school health education.

**H.E. Dr. Yung Kunthearith**
**Deputy Director of School Health Department**

## Day 2: Strengthening CPR and AED Competencies

**14 July 2026 | Phnom Penh Teacher Education College**

On the morning of 14 July 2026, the second day of **"The 3rd School Health Lecturer Training"** was held at Phnom Penh Teacher Education College, organized by STEP with support from The Nippon Foundation. The training was presided over by H.E. Dr. Yong Kunthearith, Deputy Director of the School Health Department, and H.E. Dr. Set Seng, Director of PTEC, with the participation of school health lecturers, school health teachers from PTEC attached primary and lower secondary school and student teachers of PTEC.

During the session, **Professor Saito** from Saitama University, Japan, delivered training on Cardiopulmonary Resuscitation (CPR) and the use of an Automated External Defibrillator (AED), equipping participants with essential knowledge and practical skills to respond effectively to cardiac emergencies.

The program concluded with hands-on group practice on CPR and AED operation, helping participants strengthen their confidence and emergency response skills. The training aims to enhance the capacity of school health lecturers and health teachers, improve school health education, and promote safe and healthy learning environments for students.










Strengthening Emergency Response through CPR and AED Competencies

## From Knowledge to Basic Life Support (BLS)

Building on the knowledge and practical skills introduced by Professor Saito, **Ms. Hour Khim** a school health lecturer from PTEC led a follow-up session for BTEC student teachers, transferring the key concepts and teaching methodologies on CPR. Through demonstrations and guided practice, she reinforced the essential emergency response techniques while encouraging student teachers to develop the confidence and competence to apply these life-saving skills in school settings. This cascading approach reflects STEP's commitment to strengthening the capacity of future educators and promoting sustainable school health education in Cambodia.






Ms. Hour Khim demonstrating CPR techniques as student teachers practice life-saving skills.

## Day 3: Building Practical Excellence through Hands-on Learning

**15 July 2026 | Battambang Teacher Education College**

On 15 July 2026, the third day of **"The 3rd School Health Lecturer Training"** was held at BTEC, under the presidency of **H.E. Dr. Chea Ratha**, Director of BTEC. The training brought together school health lecturers from PTEC and BTEC, along with health teachers from BTEC's attached primary and lower secondary schools and student teachers of BTEC.




*©Battambang Teacher Education College*







## Child Health as the Foundation of Learning

**H.E. Dr. Chea Ratha** emphasized that health education has become a global priority, particularly in the post-COVID-19 era. He highlighted several emerging challenges affecting children, including excessive smartphone use, reduced physical activity, impacts on physical development, and growing mental health concerns such as stress and emotional difficulties.

Concerns were also raised about excessive energy drink consumption among children, which may contribute to health problems and negatively influence concentration, learning performance, and behavior. In addition, unhealthy diets and insufficient nutrition were identified as factors affecting children's physical growth and development.

Recognizing these challenges, His excellency stressed the important role of teachers in promoting health education, as good health is fundamental to effective learning. He concluded that supporting children's health will help them learn better, reach their full potential, and become the future pillars of the nation.

**H.E. Dr. Chea Ratha**
**Director of Battambang Teacher Education College**





**Handover of 162 Primary School Health Textbooks to BTEC**

## Day 4: Developing School Health Learning Resources

**16 July 2026 | Battambang Teacher Education College**






On 16 July 2026, **"The 3rd School Health Lecturer Training"** organized by STEP with support from The Nippon Foundation, concluded successfully at BTEC.

The final day's program focused on reviewing, and revising the School Health Glossary to ensure the accurate and consistent use of technical terminology in school health education. The agreed glossary will be incorporated into the core textbook and other training materials, strengthening the quality and practical application of future teaching resources.

**Dr. Huot Sinuon** expressed appreciation to the STEP Project for its continuous support in motivating and strengthening the capacity of school health lecturers. He highlighted the value of practical CPR and AED training provided by Japanese professors, which greatly benefited both lecturers and student teachers. He expressed gratitude to The Nippon Foundation through STEP, Japanese professors, and all partners for their valuable contributions to advancing teacher education and school health development in Cambodia.

**Dr. Huot Sinuon | Deputy Director of BTEC**

### From School Context to Effective Teaching

**Ms. Masuko Yuka** introduced the objectives and plan for the school visit to the school health lecturers, emphasizing the importance of connecting teacher education with real school contexts. She explained that the visit aimed to understand the current state of School Health implementation at primary schools, identify existing practices and challenges, and use these insights to improve School Health lesson plans at the Teacher Education Colleges. This approach will help ensure that future lessons are more practical, relevant, and responsive to the actual needs of schools and students.




**MASUKO Yuka | Country Director of STEP**

### Enhancing School Health Learning Materials



**Mr. Thay Sokheng** followed up on the progress of the lower secondary School Health textbook translation and reviewed challenges encountered by school health lecturers throughout the translation process. The discussion provided an opportunity to identify key issues, share feedback, and explore practical solutions to ensure the timely completion of high-quality, accurate, and contextually appropriate learning materials.

**Thay Sokheng | Deputy Secretary General of STEP**

# The 3rd School Health Lecturer Training

## SUGOROKU – Nutrition Game

Participants explored the **SUGOROKU-Nutrition Game** with the STEP team. This interactive learning tool aims to promote nutrition education in schools by encouraging students to learn about healthy eating habits through an engaging and enjoyable approach. Through the game-based learning activities, participants gained a better understanding of how innovative teaching tools can be applied to make nutrition education more effective, interactive, and accessible for students.





## Refining the School Health Glossary



The Glossary Review Session focused on reviewing and refining key School Health terms to ensure accuracy, consistency, and clarity in learning materials. Through collaborative discussion, participants worked to establish a common understanding of technical terminology to support effective teaching and learning.



## Reflection on Internship Experience

Through my internship at NGO STEP, I gradually understood that public health and school health projects are supported by many detailed tasks that are not always visible from the outside. Before the internship, I tended to focus mainly on the content of school health, such as health education, hygiene practices, and children's behavior. However, through my daily work, I realized that behind every training session, meeting, and educational material, there are many practical tasks such as preparing documents, arranging venues, organizing materials, managing participants, taking records, and adjusting communication among stakeholders. Another important reflection was related to communication and coordination. During the training sessions, I observed that NGO staff had to communicate with many different actors, including teacher trainers, school teachers, government officers, school staff, and external partners. I learned that communication in project work is not simply exchanging information. It also requires understanding the position of each stakeholder, adjusting explanations depending on the situation, and creating a comfortable environment for discussion. NGO STEP staff made a great relationship with stakeholders like a family. I really appreciate to conduct intern NGO STEP. Thank you very much for all.

**Osaga Yuki | Nagasaki Univeristy**

